ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០០១/២៥ ន.ប.ក

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែតុលា និងទិសដៅខែវិច្ឆិកា ឆ្នាំ២០២៥

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើងជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាវំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្សជារឿងស្មុកស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិ ក្នុងពិភពលោក ដែលមិនមែនកើតឡើងដោយមូលហេតុតែមួយនោះទេ។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងពត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ កន្លងមកចំនួនដ៏ច្រើនលើសលុបនៃប្រជាជនពេញវ័យការងារ បានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹងជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់ នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។

នៅក្នុងខែតុលានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ១៦.១១៦លើក មានអ្នកចូលរួមសរុបចំនួន ៧៦៩.៨០៩នាក់ ក្នុងនោះស្ត្រី ៣៨៩.៤៨៦នាក់ (ប្រៀបធៀបនឹងខែកញ្ញាមានចំនួន ៧៤០.១៤៨នាក់) កើនឡើង ៤% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ១៥.៩៦៩ | ៧៦៥.១៩១ | ៣៨៦.៩៩១ |
| ២ | កម្មវិធីផ្សេងៗ | ១៤៧ | ៤.៦១៨ | ២.៤៩៥ |
| | សរុប | ១៦.១១៦លើក | ៧៦៩.៨០៩នាក់ | ៣៨៩.៤៨៦នាក់ |
| *(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)* | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| តារាងទិន្នន័យវេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
| | | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ១ | គ.ជ.ប.ជ | ២៦ | ២.៣២០ | ១.១៣២ | | | |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៧៦ | ៣.២៦៦ | ១.៦២៨ | ១៣ | ៤៤៥ | ២០៦ |
| ២ | កណ្តាល | ១.២៤៨ | ១៤៦.៤៧៣ | ៥៤.៦១៣ | ១៩៩ | ៧.៧៥១ | ៤.៣៤២ |
| ៣ | បាត់ដំបង | ៧៣៧ | ៣០.៧៥៧ | ១៧.៥០៥ | ៥៩១ | ១៩.៣៣៤ | ១១.១៤៩ |
| ៤ | ពោធិ៍សាត់ | ៩០៤ | ៧៧.៥២៣ | ៤៥.១៧៦ | ៥៩០ | ២១.៤៤៧ | ៥.៩៥៨ |
| ៥ | សៀមរាប | ៧៩០ | ៤៤.២២៣ | ២៨.៤១៤ | ៦៨៩ | ២៧.៦១២ | ១៧.៦០៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | កំពង់ឆ្នាំង | ៧៧៧ | ៣០.៩៥៩ | ១៥.៧៤០ | ៤៩១ | ១៥.៩២៩ | ៨.១៧៨ |
| ៧ | កំពង់ចាម | ១.៧១៦ | ១០០.៦៦៩ | ៥០.៦៣០ | | | |
| ៨ | ព្រះសីហនុ | | | | | | |
| ៩ | ព្រះវិហារ | ១៩ | ១.៦៥៦ | ៩៤៤ | | | |
| ១០ | ស្វាយរៀង | ៦៩ | ២.៩៥២ | ១.៤២០ | ១៨ | ៦៨៤ | ៣១១ |
| ១១ | ប៉ៃលិន | | | | ១១១ | ៤.០០២ | ១.៩៤៤ |
| ១២ | កោះកុង | ១.៥៣៥ | ២០.៨៤០ | ៩.១២១ | ៣៧០ | ៥.៧៨៦ | ២.៣៦៣ |
| ១៣ | កំពត | ០៨ | ៩៤ | ៣៤ | | | |
| ១៤ | កំពង់ធំ | | | | | | |
| ១៥ | តាកែវ | ៣១៥ | ១០.០៥៦ | ៥.៨២១ | | | |
| ១៦ | ក្រចេះ | ៦៣ | ៩៧៥ | ៥៤០ | | | |
| ១៧ | កែប | | | | | | |
| ១៨ | កំពង់ស្ពឺ | ៥៧៦ | ២៣.២០៤ | ១២.៤៦៣ | ១៤០ | ៦.១៤៨ | ៣.៣៥៧ |
| ១៩ | ស្ទឹងត្រែង | ២០៣ | ១១.៤៥៩ | ៦.៤៥៨ | ១៧៥ | ៦.១៤១ | ៣.៥៧៨ |
| ២០ | រតនគិរី | ៦៧៦ | ៣០.២៩៤ | ១៥.២៦០ | ៣៣៥ | ១៦.៥១៨ | ៣.៥៣១ |
| ២១ | ព្រៃវែង | ១.១០៣ | ៤៥.២១២ | ៣០.២៨៧ | ៨៩៣ | ២៩.៧៧៥ | ១៥.៨៤៩ |
| ២២ | ត្បូងឃ្មុំ | | | | ១៣១ | ៣.៧៧១ | ១.៧៤៤ |
| ២៣ | បន្ទាយមានជ័យ | | | | | | |
| ២៤ | ឧត្តរមានជ័យ | ១៥៥ | ៧.១២៨ | ៤.២៣៤ | ១៤០ | ៦.១៥២ | ៣.៧២៣ |
| ២៥ | មណ្ឌលគិរី | ៦៩ | ២.៩៥២ | ១.៤២០ | ១៨ | ៦៨៤ | ៣១១ |
| សរុប | | ១១.០៦៥លើក | ៥៩៣.០១២នាក់ | ៣០.៨៤០នាក់ | ៤.៩០៤លើក | ១៧២.១៧៩នាក់ | ៨៤.១៥១នាក់ |
| សរុបរួម | | ១៥.៩៦៩លើក | | ៧៦៥.១៩១នាក់ | | ៣៨៦.៩៩១នាក់ | |

❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃគ.ជ.ប.ជ | ០២ | ៥១៤ | |
| ២ | ខេត្តកណ្តាល | ០២ | ៤៧៦ | ១៨២ |
| ៣ | ខេត្តបាត់ដំបង | ២០ | ១.១០៨ | ៤៦២ |
| ៤ | ខេត្តប៉ៃលិន | ០២ | ១២០ | ៥៣ |
| ៥ | ខេត្តសៀមរាប | ៦៦ | ១.៨១៨ | ១.៣១១ |
| ៦ | ខេត្តកំពង់ស្ពឺ | ០២ | ៥៣ | ២០ |
| ៧ | អង្គការសោម៉ារីតាន់(បាត់ដំបង) | ០១ | ១៣៤ | ៨៣ |
| ៨ | អង្គការ Friend Internationa(សៀមរាប) | ៥១ | ៥៦៨ | ២៧៨ |
| ៩ | អង្គការម្លប់តាប៉ាង(ព្រះសីហនុ) | ០៣ | ៣៤១ | ១០៦ |
| សរុប | | ១៤៧លើក | ៤.៦១៨នាក់ | ២.៤៩៥នាក់ |

## ខ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ ការផលិត និងចែកផ្សាយសម្ភារផ្តល់ព័ត៌មាន និងអប់រំ (IEC = Information Education Communication Materials)

| ល.រ | រាជធានី ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួន ឧបករណ៍ | ចំនួនអ្នក ទទួលបាន | ចំនួន ស្ត្រី |
|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៤.៦៤៦ប័ណ្ណ | | |
| ២ | បាត់ដំបង | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៤៩២ប័ណ្ណ | | |

| | | | | | |
|---|---|---|---|---|---|
| ៣ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៧៥០ប័ណ្ណ | | |
| ៤ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ០៩ប័ណ្ណ | ៤៩២នាក់ | ១៤២នាក់ |
| | *សរុប* | | *៥.៨៩៧ប័ណ្ណ* | *៤៩២នាក់* | *១៤២នាក់* |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | សៀមរាប | -វិទ្យុជាតិ | ១២៨ | |
| ២ | ត្បូងឃ្មុំ | -វិទ្យុជាតិ | ៣២ | |
| ៣ | ប៉ៃលិន | -វិទ្យុជាតិ | ៤៩៦ | |
| ៤ | ព្រៃវែង | -វិទ្យុជាតិ | ៥០ | |
| | *សរុប* | | *៧០៦លើក* | |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ **ខេត្តសៀមរាប៖** មានតំណាងមន្ទីរកិច្ចការនារីខេត្ត មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រដ្ឋបាលស្រុកពួក និងរដ្ឋបាលស្រុកក្រឡាញ់ បានចូលរួមជាវាគ្មិន តាមវិទ្យុជាតិខេត្ត ក្រោមប្រធានបទ៖ -ការស្វែងយល់ពីអាពាហ៍ពិពាហ៍ក្នុងសង្គមខ្មែរ។ -ការផ្តល់កម្ចីឥណទានសម្រាប់បង្កើនមុខរបរដល់ពលករចំណូលស្រុក។ -ការគាំទ្រស្ត្រីឱ្យមានការងារក្រោយវិលមកពីក្រៅប្រទេស។ -និងការជួយសម្របសម្រួលដល់ជនភៀសសឹកនៅក្នុងស្រុក។

▪ **ខេត្តកំពង់ចាម៖** តំណាងមន្ទីរការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិន តាមវិទ្យុជាតិខេត្ត ស្តីពីដំណើរការទទួលនិងត្រៀមកន្លែងការងារសម្រាប់ពលករមកពីប្រទេសថៃ។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួន ០៨លើក មនុស្សចំនួន ៩៨នាក់ ស្រី ៤៥នាក់ ដោយបានធ្វើកិច្ចសន្យាអប់រំណែនាំ និងឱ្យត្រឡប់ទៅភូមិកំណើតវិញ។

### ខ.៣.២. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ ដូចមានក្នុងតារាងខាងក្រោម៖

| បរិយាយ | ចំនួនមនុស្ស | សញ្ជាតិ |
|---|---|---|
| ប្រុសបរទេសជាមួយស្រីខ្មែរ | ១៤៨នាក់ | ចិន១០៧, កូរ៉េខាងត្បូង២៦, អាម៉េរិក៨ស្រី១, បារាំង៤, វៀតណាម២ស្រី១, ឡាវ២(ស្រី), កាណាដា១, ហូឡង់១, អូស្ត្រាលី១(ស្រី), ហ្វាំងឡង់១, រុស្សី១(ស្រី)។ |
| ស្រីបរទេសជាមួយប្រុសខ្មែរ | ០៦នាក់ | |
| សរុប | ១៥៤នាក់ | ១១ សញ្ជាតិ |

❖ ការផ្សព្វផ្សាយ

▪ **ខេត្តកំពង់ចាម៖** ផ្សព្វផ្សាយ ស្តីពីការកំណត់បែបបទនិងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ដល់ប្រជាពលរដ្ឋក្រុងកំពង់ចាមចំនួន ៦៦លើក មនុស្សចូលរួមចំនួន ៣.៩៦៧នាក់ ស្រី ២.២៣៩នាក់។

### ខ.៣.៣. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

- ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន(កម្ពុជា-ថៃ)

▪ កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានទទួលពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកវិញនៅតាមច្រកផ្សេងៗ សរុបចំនួន ២៩០នាក់ ក្នុងនោះស្ត្រី ២៤នាក់។

- ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង បានទទួលពលករខ្មែរបញ្ជូនត្រលប់ពីអាជ្ញាធរថៃ សរុបចំនួន ៧៥៨នាក់ ក្នុងនោះស្ត្រី ២៤៦នាក់ (ស្ត្រីមានកូនតូចមកជាមួយ ២៩នាក់ និងស្ត្រីមានផ្ទៃពោះ ០៥នាក់) អនីតិជន ៤៤នាក់ (អនីតិជនស្រី ២២នាក់) និងជនមានពិការភាព ០៤នាក់។

### ខ.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

❖ **ការផ្សព្វផ្សាយ**

▪ ខេត្តសៀមរាបៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះជ្រើសរើស និងកំណត់អត្តសញ្ញាណកុមារងាយរងគ្រោះ ដែលមានអាណាព្យាបាលកំពុងធ្វើការនៅតាមសិប្បកម្មផលិតឥដ្ឋ ដើម្បីផ្តល់ការគាំទ្រពីគម្រោងកិច្ចអន្តរាគមន៍ស្នូល នៅក្នុងស្រុកអង្គរធំ បន្ទាយស្រី ក្រឡាញ់ សូទ្រនិគម និងស្រុកជីក្រែង ក្នុងនោះមាន ១៥សិប្បកម្ម ដែលមានកុមារសរុប ២៣៧នាក់ ស្រី ១១៥នាក់។ ជាលទ្ធផលកុមារដែលត្រូវទទួលបានពីគម្រោង មាន១៣០នាក់ ស្រី ៦៤នាក់ កុមារត្រូវទប់ស្កាត់ និងការពារ ៨០នាក់ ស្រី ៣៩នាក់ និងកុមារបន្តការគាំពារ ៥០នាក់ ស្រី ២៥នាក់ នៅក្នុងស្រុកបន្ទាយស្រី ស្រុកក្រឡាញ់ និងស្រុកសូទ្រនិគម។

▪ ខេត្តកណ្តាលៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងចងបដាផ្សព្វផ្សាយតាមសហគ្រាស គ្រឹះស្ថានក្នុងវិស័យផលិតឥដ្ឋ និងក្បឿងចំនួន៧៥សហគ្រាស/គ្រឹះស្ថាន នៅក្នុងក្រុង/ស្រុកទាំង៥ មានកម្មករនិយោជិតចំនួន ១.៦៦៩នាក់ ស្រី៨១៦នាក់ និងមានកម្មករនិយោជិតវ័យក្មេង(អាយុ១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) ៣០៣នាក់ ស្រី១៤៤នាក់ និងមានកុមាររស់នៅជុំវិញបរិវេណសហគ្រាស គ្រឹះស្ថានចំនួន ១.១៣៦នាក់ ស្រី៥៦៨នាក់។ ក្នុងនោះមន្ទីរធ្វើកិច្ចសន្យាហាមឃាត់ប្រើប្រាស់ពលកម្មកុមារ ជាមួយម្ចាស់សហគ្រាស គ្រឹះស្ថាន បានចំនួន ៧៥សហគ្រាស/គ្រឹះស្ថាន ព្រមទាំងបានធ្វើកិច្ចសន្យាជាមួយអាណាព្យាបាលចំនួន ៦៩៤គ្រួសារ។

❖ **អធិការកិច្ច**

▪ ខេត្តកណ្តាលៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើអធិការកិច្ចការងារចំនួន ៤០លើក អធិការកិច្ចការងារតាមកម្មវិធី ៣៥លើក និងអធិការកិច្ចការងារពិសេស ០៥លើក។ ធ្វើអធិការកិច្ចការងារតាមកម្មវិធីចុះត្រួតពិនិត្យលើបែបបទ ស្តីពីសហគ្រាស លក្ខខណ្ឌការងារ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសិប្បកម្មផលិតឥដ្ឋបាន ៣៥សិប្បកម្ម មានកម្មករចំនួន ៥៨៤នាក់ ស្រី ២៧២នាក់ ក្នុងនោះកុមារអាយុក្រោម១២ឆ្នាំ ១៩៦នាក់ ស្រី ៩៤នាក់ និងមានកុមារអាយុ១៥ឆ្នាំឡើង ២៨នាក់ ស្រី ១២នាក់ កំពុងរស់នៅក្នុងសិប្បកម្ម។ ក្រុមអធិការកិច្ចពុំបានរកឃើញមានការប្រើប្រាស់ និងជួញដូរកម្លាំងពលកម្មកុមារនោះទេ និងបានធ្វើកិច្ចសន្យាហាមឃាត់ប្រើប្រាស់ពលកម្មកុមារចំនួន ១០៥គ្រួសារ និងធ្វើលិខិតធានាជាមួយម្ចាស់សិប្បកម្មទាំង ៣៥សិប្បកម្ម។ ក្រោយពីបានបញ្ចប់ការធ្វើអធិការកិច្ច មាន២៥សិប្បកម្មត្រូវបានដាក់កំហិត ឱ្យម្ចាស់សិប្បកម្មត្រូវចុះឈ្មោះបង្កើតគណនីសិប្បកម្ម ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធនឹងវិស័យការងារ LACMS របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ខ.៤. ការលើកកម្ពស់ជីវភាព

❖ ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

▪ ខេត្តសៀមរាបៈ មជ្ឈមណ្ឌលការងារខេត្ត បានរៀបចំពិព័រណ៍ការងារចល័ត ចំនួន ០៣លើក មានប្រជាពលរដ្ឋចូលរួមចំនួន ៧៨៨នាក់ ស្រី ៣៨៥នាក់។ បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភពចំនួន ១៤២កន្លែង។ បានទទួលអ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន ៨៣៨នាក់ ស្រី ៤១៣នាក់ (អតីតពលករចំនួន ៦១៥នាក់ ស្រី ២៩៥នាក់)។ បានធ្វើការផ្គត់ផ្គង់និងបញ្ជូនអ្នកស្វែងរកការងារធ្វើចំនួន៨៥៩នាក់ ស្រី ៤៤៥នាក់ (ពលករ ៥៥០នាក់ ស្រី ២៩០នាក់)។ អ្នកទទួលបានការងារធ្វើចំនួន ២៥០នាក់ ស្រី ១០៨នាក់ (ពលករ ៧២នាក់ ស្រី ៣០នាក់)។ បានផ្តល់ការប្រឹក្សាយោបល់អំពីអាជីពការងារ និងវិជ្ជាជីវៈទៅអ្នកស្វែងរកការងារធ្វើ ១៩៤នាក់ ស្រី ១១៥នាក់។ អ្នកទទួលបានព័ត៌មានទីផ្សារការងារតាមរយៈខិត្តប័ណ្ណ/កម្មវិធី ១.០០០នាក់។

▪ ខេត្តកណ្តាល មានពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃចំនួន ២.៨០៣នាក់ ស្រី ១.៣៤១នាក់ ក្នុងនោះមានពលករក្នុងខេត្តបានទទួលការងារថ្មី ២.០៥៣នាក់ ស្រី ៩៣៥នាក់ និងមានពលករក្រៅខេត្តបានទទួលការងារថ្មី ១.០២០នាក់ ស្រី ៥៩៩នាក់។

▪ ខេត្តព្រៃវែង មានពលករខ្មែរដែលវិលត្រលប់ពីប្រទេសថៃចំនួន ២១.៦៤៧នាក់ ស្រី ៩.៣៨១នាក់ អ្នកទទួលបានការងារធ្វើ ១៧.២៥៤នាក់ ស្រី ៧.៤២៥នាក់។

▪ ខេត្តកំពង់ចាមៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអាជ្ញាធរទីភ្នាក់ងារ ជាតិមុខរបរនិងការងារ ប.ស.ស និងវិទ្យាស្ថានពហុបច្ចេកទេសខេត្ត ចុះផ្សព្វផ្សាយ និងចុះឈ្មោះពលករខ្មែរ រកការងារធ្វើសរុបចំនួន ២.២៧១នាក់ ស្រី ១.០១៧នាក់ ក្នុងនោះអ្នកមានការងារធ្វើ និងប្រកបមុខរបរដោយផ្ទាល់ខ្លួន ១.៥៨៨នាក់ ស្រី ៧០៧នាក់ និងមានពលករ ២៨នាក់ ស្រី ១២នាក់ ចុះឈ្មោះចូលរៀនជំនាញបច្ចេកទេសវិជ្ជាជីវៈ។

▪ ខេត្តប៉ៃលិន បានចុះស្រង់ស្ថិតិតាមសហគ្រាស គ្រឹះស្ថាន ដែលកំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិតក្នុងខេត្ត និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងពលករ។ បច្ចុប្បន្នមានសហគ្រាស គ្រឹះស្ថានចំនួន២៥ កំពុងមានតម្រូវការកម្មករនិយោជិតសរុប ១.៣៧នាក់ ស្រី ៧៨នាក់។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ៣៨ករណី (ប្រៀបធៀបខែកញ្ញា មានចំនួន ២៤ករណី កើនឡើង ១៤ករណី) ស្មើ៣៨,៣៣% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ៤៧នាក់ ស្រី ០៥នាក់ ជនសង្ស័យជាជនជាតិថៃ០១នាក់ និងជនជាតិចិន ០១នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ១០២នាក់ ស្រី ៦៣នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ ១៤នាក់ ស្រី ១៣នាក់ អាយុ១៥-១៧ឆ្នាំ ១១នាក់ ស្រី ០៩នាក់ និងអាយុ១៨ឆ្នាំឡើង ៧៧នាក់ ស្រី ៤១នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៧នាក់ គ្រួសារ ៨៥នាក់)។

  ក្នុងនោះចែកជា៖

- ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ២០/២២ករណី (ថយចុះ ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២៩នាក់ ស្រី០២នាក់ ជនជាតិថៃ ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៧០នាក់ ស្រី ៣២នាក់ មានអាយុក្រោម១៥ឆ្នាំ ០២នាក់ ស្រី ០១នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ ស្រី ០១នាក់ និងអាយុ១៨ឆ្នាំឡើង ៦៥នាក់ ស្រី ៣០នាក់ (បញ្ជូនទៅគ្រួសារទាំងអស់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| ការនាំយកអនីតិជន ជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០២ | | ០១ |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១០ | ១៣ | ថៃ១ | ១៩ |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០៨ | ១៣ | | ៤៩ |
| ការទិញពេស្យាចាកុមារ | ០១ | ០១ | | ០១ |
| *សរុប* | *២០ករណី* | *២៩នាក់* | *០១នាក់* | *៧០នាក់* |

- ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៨/០២ករណី (កើនឡើង ១៦ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៨នាក់ ស្រី ០៣នាក់ ជនជាតិចិន ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៣២នាក់ ស្រី ៣១នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ ១២នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ០៨នាក់(ស្រី) និងអាយុ១៨ឆ្នាំឡើង ១២នាក់ ស្រី ១១នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៧នាក់ គ្រួសារ ១៥នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | ចិន១ | ០១ |
| សញ្ជារកម្ម | ០២ | ០២ | | ០៨ |
| ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ០១ | ០១ | | ០៣ |
| សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០១ | | ០៦ |
| រូបភាព និងសម្ភារៈអាសអាភាស | ០២ | ០២ | | ០២ |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | | ០១ |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ | | ០៦ |
| អំពើអាសប្រថាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | | ០៥ |
| *សរុប* | *១៨ករណី* | *១៨នាក់* | *០១នាក់* | *៣២នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ

### ឃ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

- ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងប្រទេស និងក្រៅប្រទេស ចំនួន ០៣នាក់(ប្រុស ០១នាក់ ស្រី ០២នាក់) ក្នុងនោះប្រុស ០១នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម(ក្នុងប្រទេស) និងស្រី ០២នាក់ រៀបការផ្ទុយពីឆន្ទៈ(ប្រទេសចិន)។ និងបានការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញបាន ០១នាក់(ប្រុស)។

### ឃ.២. ការផ្តល់សេវា និងស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការរតនៈអ៊ីនធើណេសិនណល ចំនួន ០៣នាក់(ប្រុស ០១នាក់ ស្រី ០២នាក់)។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យរងគ្រោះ

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ០១នាក់(ស្រី)។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានការសម្របសម្រួលពីរដ្ឋបាលខេត្ត ខេត្តព្រៃវែង បានបើកវគ្គបណ្តុះបណ្តាល ស្តីពីតួនាទីភារកិច្ច និងរបៀបរបបការងារ ក្នុងរចនាសម្ព័ន្ធ គ.ខ.ប.ជ។ | ០១ | ៨១ | ៣១ |
| ២ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការម៉ារីស៊ី បើកវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងអំពីអំពើជួញដូរមនុស្ស ច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធ និងកិច្ចការពារកុមារនៅសហគមន៍ ដល់មន្ត្រីសាលាខណ្ឌ អភិបាលរង នាយករដ្ឋបាល អធិការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធាន គ.ក.ន.ក សង្កាត់ មេភូមិ និងម្ចាស់អាជីវកម្មសេវាកម្សាន្ត នៅសាលប្រជុំខណ្ឌដង្កោ។ | ០១ | ១០១ | ៣៤ |
| ៣ | ខេត្តកណ្តាល ដោយមានកិច្ចសហការ និងសម្របសម្រួលជាមួយនាយកដ្ឋានកិច្ចការពារកុមាររដ្ឋបាលក្រុងតាខ្មៅ ស្រុកកៀនស្វាយ ស្រុកកណ្តាលស្ទឹង ស្រុកអង្គស្នួល និងអង្គការសកម្មភាពដើម្បីកុមារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច ការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងសេវាគាំទ្រជូនដល់ គ.ក.ស.ក ក្រុង/ស្រុក ប្រធានការិយាល័យសង្គមកិច្ចក្រុង/ស្រុក មេឃុំ អ.ក.ន.ក មេភូមិ/អនុភូមិ និងអាណាព្យាបាលរបស់កុមារ។ | ០១ | ១២៥ | ៥១ |
| ៤ | អង្គការ Friend International (ខេត្តសៀមរាប) បានធ្វើការបណ្តុះបណ្តាលអំពីអំពើហិង្សាផ្លូវភេទ និងសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញ ដល់សិស្សានុសិស្សតាមសាលាអនុវិទ្យាល័យ និងវិទ្យាល័យ។ | ០៦ | ២៦៥ | ១៥៣ |
| | *សរុប* | *០៩វគ្គ* | *៥៧២នាក់* | *២៦៩នាក់* |

❖ ការបណ្តុះបណ្តាលនៅក្រៅប្រទេស

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់មន្ត្រីនគរបាលជាន់ខ្ពស់ចំនួន ១០រូប ទៅចូលរួមសិក្សា វគ្គបណ្តុះបណ្តាលប្រឆាំងការជួញដូរមនុស្ស (TIP) នៅមហាវិទ្យាល័យប៉ូលិសជាំស៊ី ទីក្រុងណាននិង នៃសាធារណរដ្ឋប្រជាមានិតចិន។

### គ.២. សិក្ខាសាលា

❖ សិក្ខាសាលាក្នុងប្រទេស

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្ដីពីការជំរុញការអនុវត្តយុទ្ធសាស្ត្របង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដែលប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថានចំនួន ០១លើក ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានសិក្ខាកាមចូលរួមសរុប ១៥៣នាក់ ស្រី ៥៦នាក់ នៅសាលប្រជុំទីស្ដីការក្រសួងមហាផ្ទៃ។

- ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ ដោយមានការសម្របសម្រួលពីរដ្ឋបាលខេត្តត្បូងឃ្មុំ ក្រចេះ កំពង់ចាម និងខេត្តស្ទឹងត្រែង បានរៀបចំសិក្ខាសាលាចំនួន ០៤លើក ស្ដីពីការប៉ាន់ប្រមាណអំពីគុណភាព និងប្រសិទ្ធភាពនៃគោលការណ៍ណែនាំ ស្ដីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជ. ប៊ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ មានសិក្ខាកាមចូលរួមសរុបចំនួន ២០០នាក់ ស្រី ៧៦នាក់។

❖ **សិក្ខាសាលានៅក្រៅប្រទេស**

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចាត់បញ្ជូន លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង និងជាមន្ត្រីបច្ចេកទេសទទួលបន្ទុកការងារ COMMIT ទៅចូលរួមសិក្ខាសាលា ស្ដីពី REGIONAL VALIDATION WORKSHOP ON THE SUGGESTED LIST OF COMMON INDICATORS ON TRAFFICKING IN PERSONS (TIP) FOR THE PURPOSE OF FORCED CRIMINALITY FACILITATED BY ABUSE OF TECHNOLOGY នៅខេត្ត QUANG NINH នៃសាធារណរដ្ឋសង្គមនិយមវៀតណាម រយៈពេល៣ថ្ងៃ មានបណ្ដាប្រទេសជាសមាជិក COMMT (កម្ពុជា ចិន ឡាវ ភូមា ថៃ វៀតណាម)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំចំនួន ០៦លើក មានអ្នកចូលរួមចំនួន ១៥១នាក់ ស្រី ៤៩នាក់ ក្នុងនោះ៖

- កិច្ចប្រជុំត្រួតពិនិត្យ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ៩ខែ ឆ្នាំ២០២៥ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ដោយមានសមាសភាពចូលរួមចំនួន ៨៥នាក់ ស្រី ៣០នាក់ នៅសាលប្រជុំទីស្ដីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ JICA ចំនួន ០២លើក ដើម្បីពិនិត្យលើការកែសម្រួលគោលការណ៍ណែនាំ ស្ដីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប អ្នកចូលរួមចំនួន ២៤នាក់ ស្រី ១១នាក់ សាលប្រជុំ គ.ជ.ប.ជ។

▪ កិច្ចប្រជុំអន្តរក្រសួងចំនួន ០១លើក កម្រិតបច្ចេកទេស ដើម្បីត្រៀមរៀបចំសិក្ខាសាលា ស្ដីពីការជំរុញការអនុវត្តយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយការចំណាកស្រុកដោយប្រថុយប្រថាន ដែលមានអ្នកចូលរួមចំនួន ៣០នាក់ ស្រី ០៥នាក់ នៅសាលប្រជុំទីស្ដីការក្រសួងមហាផ្ទៃ។

▪ កិច្ចប្រជុំផ្ទៃក្នុងចំនួន០២លើក អ្នកចូលរួមចំនួន ១២នាក់ ស្រី ០៣នាក់៖ -ស្ដីពីត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្ដីពី "ការជំរុញការអនុវត្តយុទ្ធសាស្ត្រ បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដែលប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន"។ និងស្ដីពីការផ្សព្វផ្សាយខ្លឹមសារ នៃកិច្ចប្រជុំជាមួយឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពីបញ្ហាជួញដូរមនុស្សតាមអនឡាញ និងការវាយតម្លៃចំណាត់ថ្នាក់ការជួញដូរមនុស្សនៅកម្ពុជា ឆ្នាំ២០២៥។

▪ **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ** បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែតុលា ត្រីមាសទី៣ ឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តបន្ត សរុបចំនួន ០៥លើក មានអ្នកចូលរួមចំនួន ៥៥៦នាក់ ស្រី ១៧៨នាក់ ក្នុងនោះមានខេត្ត៖ -សៀមរាប ០១លើក អ្នកចូលរួម ៥២នាក់ ស្រី ៣១នាក់។ -កណ្ដាល ០២លើក អ្នកចូលរួម ៤៣១នាក់ ស្រី ១៣៩នាក់។ -ព្រះវិហារ ០១លើក អ្នកចូលរួម ១៧នាក់ ស្រី ០៨នាក់។ -កំពង់ចាម ០១លើក អ្នកចូលរួម ៥៦នាក់។

❖ **ការចូលរួមកិច្ចប្រជុំនៅក្រៅប្រទេស**

▪ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់តំបន់លើកទី៣ នៃគណៈកម្មាធិការជាតិអាស៊ីអាគ្នេយ៍ប្រឆាំងការជួញដូរមនុស្ស ដែលភាគីកម្ពុជា មានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅហ្វីលីពីន លេខាទី២ នៃស្ថានទូតកម្ពុជាប្រចាំនៅហ្វីលីពីន និងប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ រៀបចំឡើងដោយក្រុមប្រឹក្សាអន្តរស្ថាប័នថ្នាក់ជាតិប្រឆាំងអំពើជួញដូរមនុស្ស ហ្វីលីពីន (IACAT) នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានចាត់បញ្ជូន ឯកឧត្តមសេនីយ៍ទោ **តែ សុថារេត** អគ្គលេខាធិការរងទៅចូលរួមកិច្ចប្រជុំ "Regional Consultation Workshops on Strengthening the Non-Punishment Principle in Trafficking in Persons Cases of Forced Criminality" នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ ដោយមានការចូលរួមពីបណ្ដាប្រទេសចំនួន១២ (កម្ពុជា ឡាវ ហ្វីលីពីន ថៃ ភូមា ឥណ្ឌូនេស៊ី វៀតណាម ប្រ៊ុយណេ ម៉ាឡេស៊ី សាំងហ្គាពួរ ទីម័រឡេស អូស្ត្រាលី) និងអង្គការអន្តរជាតិភាគីពាក់ព័ន្ធដូចជា ASEAN Sectoral Bodies, AICHR, SOMTC, OHCHR, UNODC, IOM និងCSOs សរុបចំនួន ៤៨នាក់ ស្ត្រី ២៩នាក់។

### ខ.២. ទស្សនកិច្ច

▪ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើទស្សនកិច្ចនៅមណ្ឌលថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស (TIP Center) ដែលគ្រប់គ្រងដោយ ក្រុមប្រឹក្សាអន្តរស្ថាប័នថ្នាក់ជាតិប្រឆាំងអំពើជួញដូរមនុស្ស ហ្វីលីពីន (IACAT) នៅប្រទេសហ្វីលីពីន។

### ខ.៣. ជំនួបពិភាក្សាការងារ

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ថ្នាក់ដឹកនាំ និងក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយ៖

- ជាមួយលោកស្រី **គ្រីស្ទីន ប៉ាកកូ** នាយិកាប្រតិបត្តិអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ប្រចាំនៅប្រទេសស្រីលង្កា ដើម្បីពិភាក្សាការងារត្រៀមរៀបចំទស្សនៈកិច្ច របស់គណៈប្រតិភូស្រីលង្កា នៅបន្ទប់ប្រជុំទីស្ដីការក្រសួងមហាផ្ទៃ។

- គណៈប្រតិភូប្រទេសស្រីលង្កា ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ទៅវិញទៅមក លើការងារពាក់ព័ន្ធនឹងកតិកាសញ្ញាពិភពលោក GCM នៅបន្ទប់ប្រជុំទីស្ដីការក្រសួងមហាផ្ទៃ។

- គណៈប្រតិភូប្រទេសបង់ក្លាដេស ដែលមកបំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសកម្ពុជា ជួបសម្ដែងការគួរសម និងចែករំលែកបទពិសោធន៍ អំពីកិច្ចខិតខំប្រឹងប្រែងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅបន្ទប់ប្រជុំទីស្ដីការក្រសួងមហាផ្ទៃ។

- តំណាងអង្គការ AusCam ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សាលប្រជុំ គ.ជ.ប.ជ។

▪ **ខេត្តសៀមរាប៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរកិច្ចការនារីខេត្ត រដ្ឋបាលស្រុកស្វាយលើ ស្រុកអង្គរធំ ស្រុកស្រីស្នំ និងស្រុកបន្ទាយស្រី បានទទួលជួបពិភាក្សាការងារ និងផ្តល់បទសម្ភាសន៍ប្រមូលជាតុចូល ជាមួយអង្គការភ្លែនអន្តរជាតិ អំពីស្ថានភាពទូទៅរបស់គ្រួសារពលករចំណាកស្រុក ដែលវិលត្រឡប់មកវិញ បានចំនួន ០៨លើក។

▪ **ខេត្តកំពង់ចាម** បានជួបពិភាក្សាការងារ និងប្រជុំជាមួយអង្គការ IJM ដើម្បីសម្ភោធគម្រោងពង្រឹងសមត្ថភាព គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ដើម្បីការពារពលករក្នុងបរិបទទេសន្តរប្រវេសន៍។

### គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ២៣លើក។ (ឧបសម្ព័ន្ធ)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួងស្ថាប័នមន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួងស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់

- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ...ដែលធ្វើឱ្យការបូកសរុបទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ត្រូវការរៀបចំកែលម្អ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ដោយយកចិត្តទុកដាក់បន្ថែមលើការជួញដូរ ដែលពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ ដែលមានភាព ស្មុគស្មាញ ដើម្បីឱ្យការធ្វើសកម្មភាព និងទិន្នន័យមានសង្គតិភាព និងកាន់តែជាក់លាក់
- ជនល្មើសមានកលល្បិចខ្ពស់ ក្នុងការធ្វើសកម្មភាពខុសច្បាប់ ជាប្រព័ន្ធ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់ ជាពិសេស នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ខ្វះការផ្សព្វផ្សាយអំពីលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលឆ្លើយតបទៅនឹងការចោទប្រកាន់ ជាពិសេស ករណីជនបរទេស
- ខ្វះវិធីសាស្ត្រសមស្រប និងសង្គតិភាពនៃសារអប់រំ ផ្សព្វផ្សាយ និងគម្រោងសកម្មភាពនានា ដែលអាចធ្វើឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរ គ្រប់ទំរង់ ទទួលបានប្រសិទ្ធភាព ដែលអាចឱ្យមនុស្សផ្លាស់ប្តូរឥរិយាបទមិនធ្វើទេសន្តរប្រវេសន៍ ដោយប្រថុតយប្រថាន និងគ្រោះថ្នាក់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសឆបោកតាមអនឡាញ មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ជនល្មើស និងជនរងគ្រោះ អាចជាមនុស្សតែមួយ ដែលធ្វើឱ្យការកំណត់អត្តសញ្ញាណ មានការលំបាក និងប្រើពេលយូរ ។

ករណីឆបោកតាមអនឡាញ មានពាក់ព័ន្ធនឹងសកម្មភាពជួញដូរមនុស្ស និងបទល្មើសទ្រហ្មទណ្ឌផ្សេងទៀតជាច្រើនទម្រង់ មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត ការបង្ខំឱ្យធ្វើការងារខុសច្បាប់ គំនុំសងសឹក ទំនាស់ការងារ អំពើហិង្សា យាដកម្មការងារដោយបង្ខំ ខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលត្រូវយកចិត្តទុកដាក់ខ្ពស់ និងចាំបាច់ត្រូវមានការចូលរួមពីបណ្តាក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចៀសភាពរងគ្រោះ និងកាត់បន្ថយ សក្តានុពលនៃបទល្មើស។ ការបង្កើនកាបង្ការទប់ស្កាត់ នឹងអាចការពារ មនុស្សគ្រប់វ័យ តាំងពីដំណាក់កាលដំបូង ដោយមិនរង់ចាំបទល្មើសកើតឡើង និងមានអ្នករងគ្រោះ ទើបធ្វើការស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប សង្គ្រោះ ផ្តន្ទាទោស ផ្តល់កិច្ចការពារ... ដែលជាខាតបង់ដ៏ច្រើនលើសលុប ទាំងធនធានមនុស្ស ធនធានថវិកា កេរ្តិ៍ឈ្មោះ កិត្តិយស សេចក្តីថ្លៃថ្នូរ សុខភាពរាងកាយ ផ្លូវចិត្ត រហូតដល់អាយុជីវិត ពេលវេលា ទំនាក់ទំនងសង្គម និង ជាឧបសគ្គក្នុងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រមក្នុងការទទួលខុសត្រូវ តាមវិស័យជំនាញនីមួយៗ ក៏ដូចជាការកសាងទំនុកចិត្តរវាងគ្នាដើម្បីបង្កើតជាបណ្តាញសមត្ថកិច្ចដ៏រឹងមាំការពារសុវត្ថិភាពប្រជាពលរដ្ឋ និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់ មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីចាត់តាំងមន្ត្រីឱ្យទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ដើម្បីទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល ការងាររបាយការណ៍ ការងារផែនការ និងការងាររដ្ឋបាលហិរញ្ញវត្ថុ និងទទួលបានការបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចដែល ឆ្លើយតបទៅនឹងការងារប្រឆាំងអំពើជួញដូរមនុស្ស
- ពង្រឹងរបបប្រជុំ ឱ្យបានទៀងទាត់ ដើម្បីបូកសរុប និងតាមដានការងារលទ្ធផលការងារ ដែលអនុវត្ត ផ្អែកលើផែនការ និងយុទ្ធសាស្ត្រដែលបានកំណត់ ពង្រឹងប្រសិទ្ធភាពឬកែលម្អចំណុចខ្វះខាត ក្នុងក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងផ្ញើមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឱ្យបានទាន់ពេលវេលា។

## V. ទិសដៅអនុវត្តបន្ត

ដើម្បីពង្រឹងបន្ថែមនូវកិច្ចខិតខំប្រឹងប្រែង ដែលនៅតែប្រឈមនឹងការវាយតម្លៃ មិនទាន់បានល្អប្រសើរនៅឡើយ និងដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាព តាមយុទ្ធសាស្ត្រទាំងបួនដែលបានកំណត់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាដើម្បីពង្រឹងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមដាក់ចេញនូវទិសដៅដើម្បីអនុវត្តបន្ត ដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយជាមួយបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន បន្តអនុវត្តវិធានការបង្ការទប់ស្កាត់ ដែលឈានដល់ការផ្លាស់ប្តូរឥរិយាបថ តាមរយៈការជួបប្រជុំពិភាក្សាជាក្រុមនៃវិស័យពាក់ព័ន្ធ បង្កើតសកម្មភាពរួមគ្នា ដែលបង្កើនភាពជឿជាក់ពីប្រជាពលរដ្ឋ ជាពិសេស ក្រុមជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីប្រទេសថៃ និងក្រុមប្រជាជន ដែលគៀសសឹក និងបែងចែកភារកិច្ចពង្រាយបណ្តាញ ជាកម្លាំង ឆ្ពោះទៅកាន់តំបន់គោលដៅជាអាទិភាព

២. ត្រៀមប្រកាស ឯកសារ ស្តីពីការតាមដាន វាយតម្លៃ និងសិក្សា (MEL) ដើម្បីអនុវត្តក្នុងការវាយតម្លៃផែនការយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៣. ត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែក ការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេស ពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៥. ចូលរួមកិច្ចប្រជុំបច្ចេកទេស និងកិច្ចប្រជុំកំពូល ដើម្បីពង្រឹងកិច្ចសហការ ក្នុងមហាអនុតំបន់មេគង្គ និងកិច្ចប្រជុំផ្សេងៗ ថ្នាក់តំបន់ និងជាអន្តរជាតិ

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព ការបញ្ជ្រាបតាមវេទិកាសាធារណៈ នៃគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព កម្មវិធីបុណ្យជាតិ ការរៀបចំយុទ្ធនាការទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស... និងប្រើគ្រប់លទ្ធភាព ធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេស ស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដាន ការអនុវត្ត

៨. ជំរុញតាមដានត្រួតពិនិត្យ ក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៩. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

១០.ជំរុញការអនុវត្តគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណរកភាពរងគ្រោះ ដើម្បីផ្តល់សេវាសមស្របដែលជានិយាមមិនអាចខ្វះបាន ក្នុងការអនុវត្ត

១១.ចូលរួមដោះស្រាយបញ្ហានៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម

១២.បន្តដោះស្រាយ ឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីរកប្រាក់ចំណូល តាមវិធីសាស្ត្រ ជំនាញនៃវិស័យពាក់ព័ន្ធដល់ប្រជាពលរដ្ឋ ជាពិសេស ជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនភៀសសឹក៕

ថ្ងៃ...............ខែ.......... ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី.....៦..... ខែ...មករា...ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ការដឹកនាំ សម្របសម្រួល

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - ពិធីសំណេះសំណាល និងផ្សព្វផ្សាយពីភារកិច្ចចំពោះមុខ របស់សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ក្រោមអធិតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅវិមាន៧មករា រាជធានីភ្នំពេញ
  - កិច្ចប្រជុំចង្អៀត ស្តីពីការដាក់ចំណាត់ថ្នាក់កម្ពុជាដោយក្រសួងការបរទេសសហរដ្ឋអាមេរិច ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំត្រួតពិនិត្យ របាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៩ខែ ឆ្នាំ២០២៥ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ
  - កិច្ចប្រជុំគណៈកម្មការខ្លឹមសារ ដើម្បីរៀបចំមហាសន្និបាតវិសាមញ្ញសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នៅវិមាន៧មករា រាជធានីភ្នំពេញ
  - ដឹកនាំកិច្ចពិភាក្សា ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារ ខមមីតថ្នាក់តំបន់ Regional Taskforce Meeting (RTF) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី Inter-Ministerial Meeting (IMM) លើកទី៦ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-២១ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមមូលបទ "ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក្នុងយុគសម័យឌីជីថល" តាមរយៈប្រព័ន្ធ Zoom Meeting
  - កិច្ចប្រជុំត្រីមាសទី៣ ឆ្នាំ២០២៥ របស់គម្រោងសុវត្ថិភាពទេសន្តរប្រវេសន៍កម្ពុជា ជំហានទី២ ដែលរៀបចំដោយ អង្គការការីតាសស្វីស នៅសណ្ឋាគារក្លាស់ស៊ី ខេត្តបាត់ដំបង
  - ជាអធិបតីក្នុងកម្មពិធីដាក់ឱ្យប្រើប្រាស់ ផែនការយុទ្ធសាស្ត្រជាតិ កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ **ប៉ុណ្ណ សំខាន** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - សិក្ខាសាលា ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងការសម្អាតប្រាក់ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំចង្អៀត ស្តីពីការដាក់ចំណាត់ថ្នាក់កម្ពុជាដោយក្រសួងការបរទេសសហរដ្ឋអាមេរិច ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ ពិភាក្សា និងដាក់ទិសដៅការងារសម្រាប់អនុវត្តបន្ត ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  - ធ្វើបទបង្ហាញ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឆមាសទី១ ឆ្នាំ២០២៥ នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **សុង ធវន្តី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដែលសហការរៀបចំដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅសណ្ឋាគារសាន់អែនមូន រាជធានីភ្នំពេញ
  - សិក្ខាសាលា ស្តីពីតួនាទីភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវ របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងពេញលេញ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៅសណ្ឋាគារ Empress Angkor ខេត្តសៀមរាប

- ពិធីប្រកាសផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ក្រោមអធិបតីភាព លោកជំទាវ ខៀវ បូរី រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- កិច្ចប្រជុំឆ្លុះបញ្ចាំង គម្រោង PROTECT អំពីវឌ្ឍនភាព បញ្ហាប្រឈម និងវិធីឆ្ពោះទៅមុខ ក្នុងគោលបំណង គឺដើម្បីបង្កើតផែនការដាក់លាក់របស់គម្រោង និងពិចារណា ចក្ខុវិស័យជាយុទ្ធសាស្ត្រ និងទំហំនៃការងារសម្រាប់ឆ្នាំ២០២៦ រយៈពេល២ថ្ងៃ រៀបចំដោយអង្គការ UNICEF នៅសណ្ឋាគារសាន់អែនមូនរីវើសាយដ៍ រាជធានីភ្នំពេញ
- ពិធីប្រគល់ទទួល ភេសជ្ជៈ និងគ្រឿងឧបភោគបរិភោគ ពីក្រុមហ៊ុន YHS (CAMBODIA) FOOD & BEVERAGE ជាលើកទី២ ចំនួន១,៣០៤កេស ដើម្បីផ្តល់ជូនដល់វីរៈនគរបាលការពារព្រំដែន និងជនភៀសសឹក ក្រោមការសម្របសម្រួលរបស់សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងមហាផ្ទៃ ឧបត្ថម្ភដល់ក្រសួងមហាផ្ទៃ
- ពិធីដាក់ឱ្យប្រើប្រាស់ ផែនការយុទ្ធសាស្ត្រជាតិ កតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
- សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីការពង្រឹងគោលការណ៍មិនដាក់ទណ្ឌកម្មក្នុងការជួញដូរមនុស្ស ករណីនៃឧក្រិដ្ឋកម្មដោយបង្ខំ ដែលរៀបចំរួមគ្នាដោយគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ស្តីពីសិទ្ធិមនុស្ស (AICHR) និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) ដោយមានការគាំទ្រពីកម្មវិធីប្រឆាំងការជួញដូរមនុស្សអាស៊ាន-អូស្ត្រាលី ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី Zoom ពីទីស្នាក់ការអង្គការ កម្មវិធីប្រឆាំងការជួញដូរអាស៊ាន-អូស្ត្រាលី (ASEAN-ACT) រាជធានីភ្នំពេញ។

- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (២៦ច្បាប់) លិខិតចូល (២៦ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(៣៧ច្បាប់)លិខិតចូល(១៩ច្បាប់)

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - បានចូលរួមសិក្ខាសាលាបិទគម្រោង សិទ្ធិ និងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ(ស្រ្តួល)
  - បានសិក្ខាសាលាពិគ្រោះយបល់ ស្តីពីបញ្ញសិប្បនិម្មិត និងសុវត្ថិភាពសម្រាប់កុមារ រៀបចំដោយអង្គការ ដែនដីមនុស្សហូឡង់ដ៏។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**
  - បានសហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃគ.ជ.ប.ជ ចុះបំពេញបេសកកម្ម ដើម្បីរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការយល់ដឹងពីហានីភ័យ និងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សក្នុសហគមន៍ ក្នុងឃុំចំនួន ០៤ នៃស្រុកពារាំង និងក្នុងឃុំចំនួន ០៤ នៃស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**
  - បានចូលរួមសិក្ខាសាលា រយៈពេល៣ថ្ងៃ អំពីគំរូសិក្សា (Typology) ប្រចាំឆ្នាំ២០២៥ របស់ប្រទេស អាស៊ីប៉ាស៊ីហ្វិក ស្តីពីការសំអាតប្រាក់(APG) នៅបន្ទប់ប្រជុំធនាគារជាតិកម្ពុជា។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ**
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីការពង្រឹងគោលការណ៍មិនដាក់ទណ្ឌកម្ម ក្នុងការជួញដូរមនុស្ស ករណីនៃឧក្រិដ្ឋកម្មដោយបង្ខំ តាមរយៈ Zoom Meeting រយៈពេល២ថ្ងៃ រៀបចំដោយ AICHR, ASEAN-ACT និង SOMTC នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី មានប្រតិភូចូលរួមមកពីប្រទេសថៃ ហ្វីលីពីន កម្ពុជា ឡាវ និងវៀតណាម
  - បានចូលរួមកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT) ក្រោមអធិបតីភាព លោកជំទាវ **សុង ធវ័ន្ត** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ នៅសណ្ឋាគារសាន់អែនមូន រាជធានីភ្នំពេញ
  - បានកិច្ចប្រជុំគណៈកម្មាធិការខ្លឹមសារ ដើម្បីរៀបចំឯកសារសម្រាប់មហាសន្និបាត សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅវិមាន៧មករា។